USAID
FROM THE AMERICAN PEOPLE

Health Systems Strengthening in Cambodia URC

# សម្លេង USAID HSSC

គំរោងពង្រឹងប្រពន្ធ័សុខាភិបាលកម្ពុជារបស់ ទីភ្នាក់ងារដើម្បីការអភិវឌ្ឍន៏អន្តរជាតិនៃសហរដ្ឋអាមេរិក អនុវត្តដោយអង្គការ URC

លេខ ១ ខែកក្កដា ឆ្នាំ២០០៦

# សម្លេង USAID-HSSC
# សូមស្វាគមន៍

គំរោងពង្រឹងប្រព័ន្ធសុខាភិបាលកម្ពុជារបស់ទីភ្នាក់ងារ ដើម្បីការអភិវឌ្ឍន៏អន្តរជាតិនៃសហរដ្ឋអាមេរិក ដែលបានអនុវត្តដោយអង្គការ (URC) តាំងពីខែវិច្ឆិកាឆ្នាំ២០០២។

ដើម្បីជៀសវាងការភ័ន្តច្រឡំជាមួយគំរោងពង្រឹងប្រព័ន្ធសុខាភិបាលដទៃទៀត កាលពីមុនគំរោងនេះត្រូវបានគេហៅថា ”URC”។ ឥឡូវនេះយើងចង់បញ្ជាក់ពីលក្ខណៈនៃគំរោងរបស់យើង ដូច្នេះទើបយើងបានប្តូរឈ្មោះកាត់របស់យើងអោយទៅជា**គំរោងពង្រឹងប្រព័ន្ធសុខាភិបាលកម្ពុជារបស់ទីភ្នាក់ងារ ដើម្បីការអភិវឌ្ឍន៏អន្តរជាតិនៃសហរដ្ឋអាមេរិក ដែលបានប្រតិបត្តិការដោយអង្គការ URC** ។

**USAID-HSSC** ដែលថ្មីៗនេះ ទើបតែបានបន្តគំរោងរបស់ខ្លួនរហូតដល់ខែកញ្ញាឆ្នាំ២០០៨ ដោយបានផ្តោតទៅលើកញ្ចប់នៃអន្តរាគមន៍ ដើម្បីពង្រឹងប្រព័ន្ធសុខាភិបាលសាធារណៈនៅមន្ទីរសុខាភិបាលខេត្ត និងស្រុកប្រតិបត្តិ ហើយដែលនៅក្នុងពេលជាមួយគ្នានេះ ក៏ជួយឧបត្ថម្ភនិងចូលរួមវិភាគទានដល់ការងារគោលនយោបាយនៅថ្នាក់ជាតិ ដែលគាំទ្រដល់ដំណើរការរបសមន្ទីរសុខាភិបាលខេត្ត និងស្រុកប្រតិបត្តិ ។

នៅក្នុងទំព័របន្តបន្ទាប់នៃប្រតិបត្តិព័ត៌មាននេះ លោកអ្នកនឹងបានឃើញអំពីសេចក្តីសង្ខេបនៃគំរោងសំខាន់ៗរបស់យើង។ យើងនឹងបញ្ជាក់អំពីចំណុចសំខាន់នីមួយៗនៅក្នុង**សម្លេង USAID-HSSC** ដែលចេញផ្សាយក្នុងខែក្រោយៗ។

យើងសង្ឃឹមថា លោកអ្នកនឹងរីករាយជាមួយការអានអំពីការងាររបស់យើង ហើយនឹងទាក់ទងមកយើងដើម្បីស្វែងយល់បន្ថែមទៀត។

**Peggy Cook**
នាយិកាប្រចាំប្រទេស